# គណបក្ស សម រង្ស៊ី

**SAM RAINSY PARTY**
**PARTI SAM RAINSY**

**សីលធម៌ សច្ចធម៌ យុត្តិធម៌**

## គណបក្ស សម រង្ស៊ី អំពាវនាវឱ្យមានការជ្រើសរើសមេភូមិ ប្រកបដោយលក្ខណៈប្រជាធិបតេយ្យ

យោងតាមសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃកាលពីពេលថ្មីៗនេះ ក្រុមប្រឹក្សាឃុំ-សង្កាត់នៃប្រទេសកម្ពុជាចំនួន១៦២១ ដែលត្រូវបានបោះឆ្នោតជ្រើសរើសតាំងពីឆ្នាំ២០០២ នឹងត្រូវរៀបចំជ្រើសរើសមេភូមិ អនុប្រធានភូមិ និងជំនួយការភូមិ សំរាប់ភូមិទាំងអស់ទូទាំងប្រទេសកម្ពុជាចំនួន១៣០០០ នៅក្នុង២-៣សប្តាហ៍ខាងមុខនេះ ។

គណបក្ស សម រង្ស៊ី ដែលជាគណបក្សជំទាស់នៃប្រទេសកម្ពុជា ពេញចិត្តចំពោះការរៀបចំការបោះឆ្នោតនៅក្នុងភូមិនីមួយៗ ដើម្បីនឹងអនុញ្ញាតឲ្យអ្នកភូមិធ្វើការជ្រើសរើសមេភូមិរបស់ពួកគេដោយផ្ទាល់ ។ គណបក្ស សម រង្ស៊ី នឹងបន្តជំរុញឲ្យមានវិមជ្ឈការប្រកបដោយប្រជាធិបតេយ្យ និងប្រសិទ្ធភាពយ៉ាងពិតប្រាកដ ជាពិសេសក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលគ្រោងធ្វើនៅខែមេសា ឆ្នាំ២០០៧ ខាងមុខនេះ ។

ស្ថិតក្រោមកាលៈទេសៈបច្ចុប្បន្ននេះ គណបក្ស សម រង្ស៊ី ស្នើសុំឲ្យគោរពនូវគោលការណ៍សំរាប់ការជ្រើសតាំងមេភូមិ អនុប្រធានភូមិ និងជំនួយការភូមិ ដូចខាងក្រោម :

១_ត្រូវគោរពសិទ្ធិនៃសម្លេងភាគតិច ដូចនៅក្នុងប្រទេសប្រជាធិបតេយ្យ

២_ត្រូវបណ្តុះស្មារតីនៃការបង្រួបបង្រួមជាតិ និងឯកភាពជាតិ នៅថ្នាក់មូលដ្ឋាន ឲ្យដូចនៅថ្នាក់ជាតិ

៣_ត្រូវផ្តល់ភាពយុត្តិធម៌សំរាប់ឃុំ-សង្កាត់នីមួយៗ ដោយត្រូវបែងចែកតួនាទីមេភូមិ ចំពោះគណបក្សនយោបាយនីមួយៗ ទៅតាមសមាមាត្រនៃចំនួនសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលគណបក្សនីមួយៗមាន នៅក្នុងឃុំ-សង្កាត់នោះ

៤_កិច្ចសហប្រតិបត្តិការល្អ ដែលឈរលើមូលដ្ឋាននៃប្រព័ន្ធតុល្យភាពនៅថ្នាក់មូលដ្ឋាន តម្រូវឲ្យមានការបែងចែកនៅក្នុងភូមិនីមួយៗនូវតួនាទីមេភូមិ អនុប្រធានភូមិ និងជំនួយការភូមិ ក្នុងចំណោមតំណាងមកពីគ្រប់គណបក្សនយោបាយ ដែលមានអាសនៈនៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ ។

សំរាប់គ្រប់ឃុំ-សង្កាត់ ដែលគណបក្ស សម រង្ស៊ី ទទួលបានសម្លេងភាគច្រើនលើសគេ ដោយរួមបញ្ចូលទាំងឃុំប៉ោយប៉ែត ដែលជាឃុំធំជាងគេនៃប្រទេសកម្ពុជា ដែលមានប្រជាពលរដ្ឋច្រើនជាង១០០០០០នាក់ គណបក្ស សម រង្ស៊ី នឹងគោរពយ៉ាងម៉ឺងម៉ាត់តាមគោលការណ៍ខាងលើ ។

នៅឃុំប៉ោយប៉ែត (ស្ថិតក្នុងខេត្តបន្ទាយមានជ័យ ជាប់ព្រំប្រទល់ប្រទេសថៃ) មាន១១ភូមិ និងសមាជិកក្រុមប្រឹក្សាឃុំចំនួន១១នាក់ ដែលក្នុងនោះ៥នាក់មកពីគណបក្ស សម រង្ស៊ី, ៤នាក់មកពីគណបក្សប្រជាជនកម្ពុជា និង២នាក់មកពីគណបក្សហ្វ៊ុនស៊ិនប៉ិច ។ គណបក្ស សម រង្ស៊ី ស្នើសុំឲ្យធ្វើការបែងចែកតួនាទីមេភូមិដូចតទៅ : មេភូមិ៥នាក់សំរាប់គណបក្ស សម រង្ស៊ី, មេភូមិ៤នាក់សំរាប់គណបក្សប្រជាជនកម្ពុជា និងមេភូមិ២នាក់សំរាប់គណបក្សហ្វ៊ុនស៊ិនប៉ិច ។ នៅក្នុងភូមិចំនួន៥ ដែលមេភូមិមកពីគណបក្ស សម រង្ស៊ី នឹងត្រូវមានអនុប្រធានភូមិមួយរូបមកពីគណបក្សប្រជាជនកម្ពុជា និងជំនួយការភូមិមួយរូបទៀតមកពីគណបក្សហ្វ៊ុនស៊ិនប៉ិច ៕

*ភ្នំពេញ, ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៦*

**ខុទ្ទកាល័យគណបក្ស**

**ទីស្នាក់ការកណ្តាល : ផ្ទះលេខ ៧១ មហាវិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**
Headquarters : House # 71 Sothearos Road, Phnom Penh, Kingdom of Cambodia
Tel : (855-23) 217 452 / 211 336 Fax : (855-23) 217 452 / 211 336
**E-mail address :** srphqpp@forum.org.kh, cabinet@samrainsyparty.org